**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៧ ស.ស.រ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំ រដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន លើកទី ១០ និងកិច្ចប្រជុំពាក់ព័ន្ធ

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**ប្រការ១:** បង្កើតគណៈកម្មការសំរាប់រៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន លើកទី១០ និងកិច្ចប្រជុំពាក់ព័ន្ធ ដែលប្រារព្ធធ្វើនៅខេត្ត សៀមរាប ចាប់ពីថ្ងៃទី ០២ ដល់ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៦ មានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម គាត ឈន់ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- លោកជំទាវ នាង ច័ន្ទថាណា | អគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៤- ឯកឧត្តម ឃុ. ស៊ុនឡុង | អគ្គនាយករងនគរបាលជាតិក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥- ឯកឧត្តម ហោ សុធន | អគ្គលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៦- ឯកឧត្តម គីម គុណាវឌ្ឍន៍ | អគ្គនាយកក្រសួងពត៌មាន | សមាជិក |

៧- ឯកឧត្តម ស៊ឹម ស្មន អភិបាលខេត្តសៀមរាប សមាជិក

**ប្រការ២ :** នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជា លេខាធិការដ្ឋាន របស់គណៈកម្មការរៀបចំកិច្ចប្រជុំខាងលើនេះ ។

**ប្រការ៣ :** គណៈកម្មការរៀបចំកិច្ចប្រជុំនេះមានភារកិច្ចដូចតទៅ ÷

ក- រៀបចំកម្មវិធីប្រជុំ និងពិធីការអោយបានសមស្រប

ខ- រៀបចំគំរោងចំណាយសំរាប់រៀបចំកិច្ចប្រជុំខាងលើ រួចលើកសំណើសុំថវិកាពីរាជរដ្ឋាភិបាល

គ- សំរបសំរួល រៀបចំការពារសន្តិសុខជូនគណៈប្រតិភូ និងសមាជិកអង្គប្រជុំអោយមានសុវត្ថិភាព

ឃ- ចាត់ចែងការសំដែងសិល្បៈប្រពៃណី ជូនគណៈប្រតិភូក្នុងក្របខ័ណ្ឌជាតិ និងភាគរៈអន្តរជាតិ

ង- សំរបសំរួល និងចាត់ចែងការធ្វើដំណើរទស្សនាចរជូនគណៈប្រតិភូ ក្រោយកិច្ចប្រជុំ តាមកម្មវិធីដែលបានគ្រោងទុក

ច- សំរបសំរួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីធ្វើការផ្សព្វផ្សាយពីកិច្ចប្រជុំនេះ ។

**ប្រការ៤ :** ប្រធានគណៈកម្មការរៀបចំកិច្ចប្រជុំនេះ មានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធនានាមកចូលរួមប្រជុំដើម្បីពិភាក្សា និងដោះស្រាយការងារដែលចាំបាច់ ។

**ប្រការ៥ :** ប្រធានគណៈកម្មការរៀបចំកិច្ចប្រជុំនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងៗតាមការចាំបាច់ ។

**ប្រការ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៧ ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ១ និងប្រការ៦
- ឯកសារ-កាលប្បវត្តិ